ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០១៣.៤ សប្រក

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី ផលប៉ះពាល់លើប្រជាពលរដ្ឋ និងតំបន់ស៊ីវិលកម្ពុជា ដោយអំពើឈ្លានពានរបស់ភាគីថៃ**
**ចាប់ពីម៉ោង១រសៀល រហូតដល់ម៉ោង៦ល្ងាច ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥**

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនថា គិតចាប់ពី ម៉ោង១រសៀល រហូតដល់ម៉ោង៦ល្ងាច ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ នេះ អំពើឈ្លានពានរំលោភច្បាប់អន្តរជាតិ និងក្បត់បទឈប់បាញ់មកលើដែនអធិបតេយ្យកម្ពុជារបស់ភាគីថៃ ដែលផ្តើមឡើងជាថ្មីកាលពីថ្ងៃទី៧ ខែធ្នូ បានបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុវត្ថិភាពប្រជាពលរដ្ឋ និងតំបន់ស៊ីវិលកម្ពុជា ដូចខាងក្រោម៖

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖** ពុំមានករណីស្លាប់ និងរបួសថ្មីទេ។ ដូច្នេះ គិតមកដល់ពេលនេះ ករណីពលរដ្ឋស្លាប់មានចំនួន១១នាក់ និងរបួសចំនួន៥៩នាក់។

**២-ករណីពលរដ្ឋនៅជំរំសុវត្ថិភាព៖** ក្នុងខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កោះកុង និងខេត្តសៀមរាប មានជនភៀសសឹកសរុប **១១២.៦៤៨គ្រួសារ** (កើន៦.០៩០គ្រួសារ) ស្មើនឹងមនុស្ស **៣៧៩.០៤៧ នាក់** (កើន២២.០៩៩នាក់) ក្នុងនោះស្ត្រីមាន ១៩៧.១២៧នាក់ និងកុមារមាន ៩៤.៣៤៨នាក់។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** មានផ្ទះសំបែង និងសម្ភារប្រើប្រាស់របស់ប្រជាពលរដ្ឋ អគារក្រុមហ៊ុន អគាររដ្ឋបាល សាលារៀន វត្តអារាម ប្រាសាទបុរាណ ផ្លូវថ្នល់ និងអង្គភាពសាធារណៈជាច្រើនកន្លែង បានកំពុងរងការខូចខាតជាបន្តបន្ទាប់ ខណៈសេវាជាមូលដ្ឋាន ដូចជា សេវារដ្ឋបាល សុខាភិបាល និងអប់រំនៅតាមក្រុង ស្រុក ឃុំ-សង្កាត់ ត្រូវបានផ្អាកស្ទើរទាំងស្រុង ដោយសារតែភាគីថៃបង្កើនការវាយប្រហារដោយអាវុធគ្រប់ធុន និងគ្រប់ទម្រង់មកលើតំបន់ស៊ីវិល។ របាយការណ៍ចុងក្រោយ ថៃបានប្រើយន្តហោះ F-16 ទម្លាក់គ្រាប់ផ្តាច់ស្ពានជ័យជំនះ ជាលើកទី២ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ បណ្តាលឱ្យខូចខាតទាំងស្រុង។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** ប្រកាសគាំទ្រ និងជឿជាក់យ៉ាងមុតមាំលើយុទ្ធសាស្ត្រការពារជាតិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអគ្គកស្តុកាជាន់ខ្ពស់ នៃកងកម្លាំងប្រដាប់អាវុធកម្ពុជា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីដ៏អង់អាចស្វាហាប់ ដែលក្រោមការដឹកនាំបញ្ញាប្រកបដោយយុទ្ធសាស្ត្រ របស់ **សម្តេច** ទាំងទ្វេ កម្លាំងកងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែននៃក្រសួងមហាផ្ទៃ បានកំពុងប្រកៀកស្មារួមគ្នាការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ដោយម្ចាស់ការ អង់អាចក្លាហាន ឈរជើងយ៉ាងរឹងមាំ និងមានប្រៀបឈ្នះគ្រប់គោលដៅនៃសមរភូមិប្រយុទ្ធ។

ថ្ងៃសៅរ៍ ៨រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥

**Press Release**

**The Impacts on Civilian Areas and Casualties Caused by Thailand's Aggression on Cambodia's Sovereign Territory From 1:00 PM until 6:00 PM on 13 December 2025**

**The Ministry of Interior of the Royal Government of Cambodia** would like to inform the national and international community that, from 1:00 PM until 6:00 PM on 13 December 2025, the violation of international law and breach of the ceasefire by the Thai side against Cambodia's sovereign territory since 7 December - has caused severe impacts on the safety of civilians, and civilian areas as follows:

1. **Deaths and Injuries**: As of 6:00 PM on 13 December 2025, the total number of Cambodian civilians killed has reached 11, and the number of injured has reached 59. **(There are no new figures currently.)**
2. **Displacement of Civilians:** In the provinces of Preah Vihear, Oddar Meanchey, Banteay Meanchey, Battambang, Pursat, Koh Kong, and Siem Reap, there are a total of **112,648 displaced families** (increased by 6,090 families), equivalent to **379,047 people** (increased by 22,099 people). Among them are 197,127 women and 94,348 children.
3. **Destruction of Civilian Infrastructure and Disruption of Public Services:** Numerous civilian homes and personal belongings, private company buildings, administrative offices, schools, pagodas, ancient temples, roads, and various public facilities have continued to sustain damage. Meanwhile, essential public services—such as administrative services, healthcare, and education across cities, districts, and communes (sangkats)—have been almost entirely suspended due to Thailand's intensified attacks using all types and forms of weapons against civilian areas. The latest report indicates that Thailand deployed F-16 aircraft to carry out a second bombing of the Chey Chumneas Bridge in Veal Veng district, Pursat province, resulting in its complete destruction.

**The Ministry of Interior of the Royal Government of Cambodia** once again firmly reiterates its full support and unwavering confidence in **Samdech Akka Moha Sena Padei Techo Hun Sen**, President of the Senate and Senior Logistic Commander of the Royal Cambodian Armed Forces, and **Samdech Moha Borvor Thipadei Hun Manet**, the courageous and capable Prime Minister of Cambodia. Under the strategic leadership and experienced guidance of **Samdech Techo** and **Samdech Thipadei**, the forces of the Royal Cambodian Armed Forces and the Border Protection Police of the Ministry of Interior are jointly standing guard to defend the territorial integrity and national sovereignty with discipline, bravery, and determination, standing firmly and successfully achieving every objective on the battlefield.

Phnom Penh, December 13, 2025